ជូនចំពោះមាតាបិតា/អាណាព្យាបាល៖

ក្នុងពេលថ្មីៗនេះ យើងបានកត់សម្គាល់ឃើញថាចំនួនក្មេងដែលមានចៃបានកើនឡើងនៅក្នុងសាលារបស់យើង។ ក្នុងចំណោមជម្ងឺឆ្លងរបស់ក្មេង មានតែរោគផ្តាសាយធម្មតាទេដែលកើតមានឡើងញឹកញាប់ជាងការឆ្លងចៃ។ ដោយហេតុនេះហើយ ពេលណាយើងដឹងថាសិស្សណាម្នាក់មានចៃ យើងនឹងមិនឲ្យសិស្សនោះមករៀន រហូតដល់ពេលមានការចាប់ផ្តើមធ្វើការបំបាត់ចៃឲ្យបានត្រឹមត្រូវសព្វគ្រប់សិន។

អ្នកណាម្នាក់ក៏អាចឆ្លងចៃបានដែរ។ តាមពិត ក្បាលដែលស្អាតបាត ច្រើនឆ្លងចៃជាងក្បាលដែលក្រខ្វក់ ឬក្បាល មានអង្គែ។ តាមធម្មតា ចៃមិនចម្លងរោគទេ ប៉ុន្តែវាអាចឆ្លងបានយ៉ាងឆាប់រហ័ស ប្រសិនបើគ្មានការទប់ស្កាត់ជាបន្ទាន់ នៅពេលគេឃើញមានចៃ ឬពងរបស់វា។ មាតាបិតាដែលមានការប្រុងប្រយ័ត្ន ត្រូវតែជួយយើងខ្ញុំបំបាត់បញ្ហានេះនៅសាលា និងនៅក្នុងសហគមន៍របស់យើង។

ជាទូទៅ ចៃឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមការប៉ះពាល់គ្នា និងតាមការប្រើរបស់របរចូលគ្នា ដូចជា ក្រាសសិតសក់ មួក កន្សែង និង អាវរងា។

ខ្ញុំស្នើសុំការចូលរួមសហការពីលោកអ្នក និងសូមឲ្យលោកអ្នកធ្វើតាមការណែនាំដូចមានខាងក្រោមនេះ៖

ពិនិត្យមើលកូនរបស់លោកអ្នក រកមើលសញ្ញាដែលចាប់ផ្តើមឆ្លងចៃ។ ការអេះក្បាល និងរមាស់លលាដ៍ក្បាលខ្លាំង ជាសញ្ញាដ៏សំខាន់ ថាមានចៃ។ ប្រើពន្លឺដែលភ្លឺល្អ និងកែវពង្រីក ដើម្បីពិនិត្យមើលសក់ និងលលាដ៍ក្បាល។ រកមើលសត្វតូចពណ៌ប្រផេះដែលវារ និង/ឬ ពង រាងពងក្រពើពណ៌ស ដែលជាប់នឹងសក់ ប្រហែល ១/៤ អ៊ិញ លើលលាដ៍ក្បាល។

**ទោះបីនេះជាបញ្ហាដែលធ្វើឲ្យរំខានក៏ដោយ ក៏ការឆ្លងចៃ មិនគួរជារឿងដែលបង្កើតឲ្យមានការភ្ញាក់ផ្អើលនោះទេ...វាគ្រាន់តែជា ការដែលត្រូវឆាប់ធ្វើសកម្មភាពតែប៉ុណ្ណោះ។** ភាគច្រើន គឺគ្រាន់តែតម្រូវឲ្យមានការកក់សក់ ដោយប្រើ សាប៊ូបំបាត់ចៃ សាប៊ូថ្នាំ ដែលមានលក់នៅតាមឱសថស្ថានក្នុងតំបន់ដែលលោកអ្នករស់នៅ ដោយមិនត្រូវការវេជ្ជបញ្ជា ឬត្រូវការវេជ្ជបញ្ជា ពីវេជ្ជបណ្ឌិតរបស់លោកអ្នក។ អ្នកដែលរស់នៅក្នុងផ្ទះជាមួយអ្នកឆ្លងចៃ ទាំងអស់ គួរពិនិត្យមើលចៃ និងពងចៃ ឲ្យបានគ្រប់គ្នា។ អ្នកដែលមានចៃគួរទទួលការព្យាបាល។

ក្រៅពីការកក់សក់ បើអាចធ្វើទៅបាន គួរធ្វើការបំបាត់ចៃនៅលើ ក្រាសសិតសក់ សម្លៀកបំពាក់ សម្ភារៈសម្រាប់គេង និង ស្រោមស្រោបសម្ភារៈផ្សេងៗ។ តាមធម្មតា ការចម្លងចៃ កើតមានឡើងនៅពេលដែលអ្នកមានចៃមិនរាយការណ៍ ដោយសារការយល់ខុស ខ្លាចខ្មាស់គេ ចំពោះបញ្ហានេះ។ ប៉ុន្តែបើគេដឹង រាយការណ៍ជាបន្ទាន់ និងព្យាបាលតាមវិធីត្រឹមត្រូវ បញ្ហានេះអាចបំបាត់ចោលបានយ៉ាងឆាប់រហ័ស និងងាយស្រួលបំផុត។

ដោយសេចក្តីស្មោះស្ម័គ្រ

____________________

នាយកសាលា

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវិបសៃ៖
www.philasd.org/language/khmer